ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)

កិច្ចប្រជុំលើកទី 21

ថ្ងៃព្រហស្បតិ៍ ទី 21 ខែសីហា ឆ្នាំ 2025

ទីតាំង៖ Drury High School, 1130 Church St, North Adams, MA, 01247
ម៉ោង 6:30 ល្ងាច ដល់ 8:00 យប់

<u>កំណត់ហេតុកិច្ចប្រជុំ</u>

ទីកន្លែងប្រជុំ៖ ដោយផ្ទាល់

ឯកសារកិច្ចប្រជុំ៖ របៀបវារៈ ស្លាយ

សមាជិកក្រុមប្រឹក្សា

- María Belén Power អនុរដ្ឋលេខាក្រុមប្រឹក្សា EEA ផ្នែកយុត្តិធម៌បរិស្ថាន និងសមធម៌ (EJ & Equity) (ផ្ទាល់)
- Marcos Luna -ផ្ទាល់
- Jen Salinetti - ផ្ទាល់

- Kalila Barnett - ពីចម្ងាយ
- Madeline Fraser Cook - ពីចម្ងាយ
- Melissa Ferretti - ពីចម្ងាយ
- Patricia Spence - ពីចម្ងាយ

- Cheryll Holley- អវត្តមាន
- Caroline Hon- អវត្តមាន
- Lydia Lowe- អវត្តមាន
- Peter Maathey- អវត្តមាន
- Sofia Owen- អវត្តមាន
- Ari Zorn - អវត្តមាន
- Miles Gresham- អវត្តមាន

1. **មតិស្វាគមន៍ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ**
   María Belén Power បានស្វាគមន៍អ្នកចូលរួមទាំងអស់។

   Sophia Spungin បានជម្រាបជូនពីទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ រួមទាំងការប្រើប្រាស់ប្រអប់សំណួរនិងចម្លើយ (Q&A) និងលទ្ធភាពអាចទទួលបានអ្នកបកប្រែផ្ទាល់មាត់។

2. **ទិដ្ឋភាពទូទៅនៃរបៀបវារៈ**

   **María Belén Power** បានរំលឹកឡើងវិញអំពីរបៀបវារៈនៃកិច្ចប្រជុំ។

3. **ការហៅឈ្មោះសមាជិក/ការអនុម័តលើកំណត់ហេតុប្រជុំពីមុន**

**María Belén** បានធ្វើការហៅឈ្មោះសមាជិកក្រុមប្រឹក្សា EJC។ នៅពេលចាប់ផ្តើមកិច្ចប្រជុំ សមាជិកក្រុមប្រឹក្សាដូចខាងក្រោម បានមានវត្តមានចូលរួម៖ Marcos Luna, Jen Salinetti, Kalila Barnett, Madeline Fraser Cook, Melissa Ferretti, និង Patricia Spence ។

សមាជិកក្រុមប្រឹក្សាដូចខាងក្រោមមិនមានវត្តមានចូលរួម៖ Cheryll Holley, Caroline Hon, Lydia Lowe, Peter Maathey, Sofia Owen, Ari Zorn, និង Miles Gresham។

**María Belén** ទទួលស្គាល់ថាខ្វះកូរ៉ុមសម្រាប់កិច្ចប្រជុំនេះ។ បើគ្មានកូរ៉ុម សមាជិកក្រុមប្រឹក្សានឹងមិនរៀបចំបោះឆ្នោត ឬធ្វើការសម្រេចអ្វីឡើយ។

4. **វគ្គសំណួរនិងចម្លើយជាសាធារណៈលើកទីមួយ**

អ្នកចូលរួមសាធារណៈតាមប្រព័ន្ធអ៊ីនធឺណិត បានផ្តល់យោបល់និងសំណួរ៖

- អ្នកចូលរួមម្នាក់បានស្នើសុំឱ្យមានការកែប្រែទៅលើកំណត់ហេតុកិច្ចប្រជុំ EJC លើកទី 17 ដោយកែតម្រូវប្រភពដើមនៃអង្គការ (ទីក្រុង Taunton ម៉ាសាឈូសេត )។ អ្នកចូលរួមបានសម្តែងការព្រួយបារម្ភលើបញ្ហាសុវត្ថិភាពសាធារណៈបរិស្ថាន និងបញ្ហាសុខភាពនៅទីក្រុង Taunton រដ្ឋម៉ាសាឈូសេត។
- អ្នកចូលរួមម្នាក់បានសម្តែងការព្រួយបារម្ភលើការបញ្ចប់ជំនួយយុត្តិធម៌បរិស្ថាន ភាពទៀងទាត់នៃលទ្ធភាពចូលរួមនិងបរិយាបន្នក្នុងកិច្ចប្រជុំនានា នៃទីភ្នាក់ងារការិយាល័យប្រតិបត្តិរដ្ឋម៉ាសាឈូសេត។

5. **បទបង្ហាញស្តីពីច្បាប់ម៉ាសាឈូសេតរ៉េឌី (ពន្ធគយបរិស្ថាន)**

វាគ្មិនកិត្តិយស លោកស្រី **Stephanie Cooper ជាអនុរដ្ឋលេខាធិការបរិស្ថាន** មកពី**ការិយាល័យប្រតិបត្តិថាមពល និងកិច្ចការបរិស្ថានម៉ាសាឈូសេត** បានផ្តល់បទបង្ហាញសង្ខេបស្តីពីច្បាប់ស្តីពីការត្រៀមលក្ខណៈរបស់រដ្ឋម៉ាសាឈូសេត (Massachusetts Ready Act)។ ច្បាប់ត្រៀមលក្ខណៈរបស់រដ្ឋម៉ាសាឈូសេត មានមុខងារពង្រឹងនិងការពារសហគមន៍ក្នុងការឆ្លើយតបទៅនឹងបញ្ហា ប្រឈមនៃការប្រែប្រួលអាកាសធាតុ។ លោកស្រីអនុរដ្ឋលេខាធិការ Cooper បានគូសបញ្ជាក់អំពីផែនការដែលបានធ្វើឡើង ដើម្បីបង្កើតគោលដៅយុទ្ធសាស្ត្រក្នុង ការសម្រេចបាននូវហេដ្ឋារចនាសម្ព័ន្ធធន់ទ្រាំ ការស្តារទន្លេ ការជួសជុលឧទ្យានរដ្ឋ ការកាត់បន្ថយសំណល់រឹង ការផ្តល់អាទិភាពដល់ធម្មជាតិ និងការដោះស្រាយបញ្ហា បំពុលបរិស្ថាន។

សមាជិកក្រុមប្រឹក្សាបានសាកសួរអំពីសមត្ថភាពរបស់ក្រុមប្រឹក្សាក្នុងការផ្តល់មតិចូលរួមលើដំណើរការ ព័ត៌មានលម្អិតនៃមូលនិធិកម្ចីបង្វិល កង្វល់ទាក់ទងនឹងការលើកលែង ការរឹតបន្តឹងការអនុញ្ញាតដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិច គោលការណ៍ណែនាំនិងដំណើរការលទ្ធកម្ម និងឱកាសដែល EJC មានដើម្បីលើកកម្ពស់សហគមន៍ EJ និងអង្គការតាមសហគមន៍។

6. **វគ្គសំណួរ និងចម្លើយសាធារណៈលើកទី 2**
ទាំងសាធារណៈជនចូលរួមតាមអនឡាញនិងដោយផ្ទាល់ សុទ្ធតែបានផ្ដល់មតិយោបល់ សំណួរ និងស្នើសុំ។
   - អ្នកចូលរួមសាធារណៈម្នាក់បានជំរុញឱ្យផ្ដល់ជូនមូលនិធិបង្វិលដល់សហគមន៍ដែលជួបការលំបាក និងចុងក្រោយគឺលទ្ធភាពក្នុងការអនុគ្រោះលើមូលនិធិកម្ចីទាំងនោះ។ បន្ថែមពីនេះ អ្នកចូលរួមបានទទួលស្គាល់ការលំបាកក្នុងការរក្សាមូលនិធិជំនួយដែលអាចសងមកវិញបានសម្រាប់ក្រុមយុត្តិធម៌បរិស្ថានខ្នាតតូចនិងក្នុងស្រុក។ ទាក់ទងនឹងលទ្ធភាពទទួលបានសេវាភាសា អ្នកចូលរួមបានលើកទឹកចិត្តឱ្យមានលទ្ធភាពផ្ដល់ជូនសំណើសុំមូលនិធិជំនួយជាច្រើនភាសា។
   - អ្នកចូលរួមតាមអនឡាញម្នាក់បានសម្ដែងការព្រួយបារម្ភចំពោះការលុបចោលឯកសារយោងពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាននិងភាពចម្រុះ។ ម្យ៉ាងទៀត អ្នកចូលរួមបានស្នើសុំឱ្យប្រជាជនយុត្តិធម៌បរិស្ថាននៅតំបន់ Cape Cod អាចផ្ដល់មតិចូលរួមនៅក្នុងកម្មវិធី Superfund។
   - អ្នកចូលរួមតាមអនឡាញម្នាក់បានសម្ដែងការព្រួយបារម្ភអំពីការមិនអាចទទួលបានចម្លើយពីនាយកដ្ឋានអភិរក្សនិងការកម្សាន្ត។
   - អ្នកចូលរួមតាមអនឡាញម្នាក់មកពីខោនធី Berkshire បានសម្ដែងការព្រួយបារម្ភចំពោះវិបត្តិទាក់ទងនឹងសុខភាពនៅទីក្រុង Pittsfield រដ្ឋម៉ាសាឈូសេត។ នេះរួមបញ្ចូលទាំងបញ្ហាពាក់ព័ន្ធនឹងសុខភាព ជាប់ទាក់ទងនឹងការស្ថិតនៅជិតទីតាំងកម្មវិធី Superfund។
   - អ្នកចូលរួមសាធារណៈម្នាក់មកពីតំបន់ Berkshires បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការផ្ដល់អាទិភាពដល់ទិដ្ឋភាព "តូចៗ" (ឧ. លទ្ធភាពទទួលបានសេវាភាសា ឱកាសមូលនិធិជំនួយដែលសហគមន៍អាចចូលរួមបាន) ដែលជាក់ស្ដែងសម្រាប់សហគមន៍តូចៗ។ អ្នកចូលរួមបានលើកទឹកចិត្តឱ្យមានទំនាក់ទំនងដោយផ្ទាល់ជាមួយសហគមន៍។

**មតិយោបល់ពីសំណួរនិងចម្លើយ មានរៀបរាប់ដូចខាងក្រោម៖**

| # | សំណួរ | ឈ្មោះអ្នកសួរ | ចម្លើយ |
|---|---|---|---|
| **1** | ចុះចំណែកការអភិវឌ្ឍន៍កម្លាំងពលកម្មសម្រាប់កសិកម្មនិងការនេសាទ ការងារទាក់ទងនឹងការកម្សាន្តតាមផ្លូវទឹក អាជីវកម្មអង្គភាពអភិរក្សយុវជនរបស់យើង (Our Youth Conservation Corps) កម្មសិក្សាសម្រាប់យុវជននិងការអភិវឌ្ឍអាជីពនៅក្នុងឧស្សាហកម្មបរិស្ថានវិញ? | លោក John G Andrade | យល់ស្របថា ទាំងអស់នេះគឺសំខាន់ណាស់ ហើយជាអ្វីដែលយើងគាំទ្រ ឧទាហរណ៍ កម្មវិធីអាហារូបករណ៍អភិរក្ស (Conservation Fellows) របស់ DCR និងក្រុមប្រឹក្សាភាពជាអ្នកដឹកនាំយុវជនរបស់ MDAR ដែលត្រូវបានគាំទ្រដោយមូលនិធិដំណើរការ។ |

| | | | |
|---|---|---|---|
| **2** | តើការគាំទ្រកសិដ្ឋានមានន័យដូចម្តេច ប្រសិនបើវាមិនមែនមានន័យថាផ្តល់ឱ្យកសិដ្ឋាននូវលទ្ធភាពទទួលបានមូលនិធិបន្ថែមទៀតសម្រាប់ការបន្សាំទៅនឹងអាកាសធាតុនោះ? តើនោះគ្រាន់តែជាការបែងចែកមូលនិធិសម្រាប់កម្មវិធីដែលមានស្រាប់ឬ? | Angela Roell | សេចក្តីព្រាងច្បាប់នេះនឹងអនុញ្ញាតឱ្យមានកម្មវិធីផ្តល់មូលនិធិជាច្រើនប្រភេទ ដើម្បីគាំទ្រដល់កសិដ្ឋានដូចបានរៀបរាប់នៅទីនេះhttps://www.mass.gov/guides/agricultural-grants-and-financial-assistance-programs |

7. **ជំហានបន្ទាប់ និងការលើកវារកាល**
   **María Belén** បានរំលឹកសមាជិកក្រុមប្រឹក្សាអំពីកិច្ចប្រជុំបន្ទាប់នៅ**ថ្ងៃទី 23 ខែតុលា** នៅទីក្រុង **Pittsfield រដ្ឋម៉ាសាឈូសេត**។

   **María Belén** បានបញ្ចប់កិច្ចប្រជុំនៅវេលាម៉ោង 8:33 យប់។